ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ ១១៤៨ សអត

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ តុលា ឆ្នាំ ២០០៣

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈកម្មការរៀបចំការងារចុះបញ្ជីអត្រានុកូលដ្ឋានចល័តនៅកម្ពុជា

## សមាករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកត/១៩៦-០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ ។
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ ។
- យោងតាមអង្គប្រជុំរវាងនាយកដ្ឋានរដ្ឋបាលទូទៅ និង នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ជាមួយ ធនាគារអភិវឌ្ឍន៍អាស៊ី ។
- យោងតាមសំណូមពរភារកិច្ច ចាំបាច់ ។

## សំរេច

**ប្រការ១ :** ត្រូវបានបង្កើតគណៈកម្មការរៀបចំការងារចុះបញ្ជីអត្រានុកូលដ្ឋានចល័តនៅកម្ពុជា ដែលមានសមាសភាព ដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| - ឯកឧត្តម | សក់ សេដ្ឋា | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល | ប្រធាន |
| - លោក | អ៊ុច សារុ | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល | អនុប្រធាន |
| - លោក | ទៅ វណ្ណណី | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល | អនុប្រធាន |
| - លោក | ឡាយ គឹមឡេនៈ | ប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ | សមាជិកអចិន្ត្រៃយ៍ |
| - លោក | ឈេង ទី | ប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន | សមាជិក |
| - លោក | ចាន់ សុវណ្ណា | អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ | សមាជិក |
| - លោក | នួន ម៉ុនថាល់ | អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ | សមាជិក |

vana

- លោក ស្រ៊ី សំខាន់ អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ សមាជិក
- លោក សៀម ឆេងអាន ប្រធានការិយាល័យស្ថិតិ និង អត្រានុកូលដ្ឋាន នៃនាយកដ្ឋានរដ្ឋបាលទូទៅ សមាជិក
- លោក នី គីមសាន ប្រធានការិយាល័យស្រាវជ្រាវ នៃនាយកដ្ឋានរដ្ឋបាល-មូលដ្ឋាន សមាជិក
- លោក **Pavinder Singh** អ្នកពិគ្រោះយោបល់ នៃគំរោង ADB លើការងារអត្រានុកូលដ្ឋាន

**ប្រការ២ :** គណៈកម្មការនេះមានភារកិច្ច ÷

- រៀបចំខ្លឹមសារ ឯកសារផ្សេងៗ និង នីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋាន ។
- រៀបចំកម្មវិធីចុះស្រាវជ្រាវ ស្ទាបស្ទង់ជាក់ស្តែងនៅតាមខេត្ត ដែលត្រូវធ្វើការសាកល្បងក្នុងការចុះបញ្ជីអត្រានុកូលដ្ឋានចល័ត ។
- សហការជាមួយជំនាញការ និង ក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យ កែសំរួល ឬ បំពេញបន្ថែមនូវ លិខិតបទដ្ឋានមួយចំនួនដែលពាក់ព័ន្ធទៅនឹងការងារអត្រានុកូលដ្ឋាន ។
- គ្រោងរៀបចំពេលវេលា ទីកន្លែង សំភារៈ ថវិកា សំរាប់ធ្វើការហ្វឹកហ្វឺនបណ្តុះបណ្តាលមន្ត្រីអត្រានុកូលដ្ឋាននៅថ្នាក់ជាតិ ខេត្ត ក្រុង ស្រុក ខណ្ឌ និង ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ ទូទាំងប្រទេសអំពីការងារអត្រានុកូលដ្ឋាន ។
- រៀបចំខ្លឹមសារ ផ្ទាំងគំនូរ រូបភាពគ្រប់ប្រភេទសំរាប់ឃោសនាផ្សព្វផ្សាយ និង សំរាប់ការងារអប់រំហ្វឹកហ្វឺន សាធារណៈជន ។
- រៀបចំបូកសរុបលទ្ធផលយុទ្ធនាការ នៃការចុះបញ្ជីអត្រានុកូលដ្ឋានចល័ត និង ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ តាមពេលវេលាកំណត់ ។

**ប្រការ៣ :** គណៈកម្មការនេះត្រូវចូលរួមប្រជុំក្នុងពីរសប្តាហ៍ម្តង និង ប្រជុំវិសាមញ្ញក្នុងពេលមានការចាំបាច់តាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការ ។

**ប្រការ៤ :** គណៈកម្មការនេះ មានសិទ្ធិចាត់តាំងមន្ត្រី ដែលស្ថិតក្រោមឱវាទ ទីស្តីការក្រសួង ដើម្បីជួយការងារតាមការចាំបាច់ ។

**ប្រការ៥ :** អគ្គលេខាធិការដ្ឋាន អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាលនិងនគរបាល អគ្គនាយកដ្ឋានរដ្ឋបាល និង ឯកឧត្តម អស់លោក ដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តី សំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ចម្លងជូន :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងយុត្តិធម៌
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  " ដើម្បីជូនជ្រាប "
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ១ និង ប្រការ៥
  " ដើម្បីមុខការ "
- ឯកសារ កាលប្បវត្តិ

vana